ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២៤-៥៧១ ប្រក

# ប្រកាស
# ស្តីពី
# ហានិភ័យប្រតិបត្តិការសម្រាប់អនុបាតភាពគ្រប់គ្រាន់នៃដើមទុន របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការតែងតាំង លោកជំទាវ **ជា សិរី** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់ធនាគារជាតិនៃកម្ពុជា

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងផ្តល់វិធានសម្រាប់វាស់វែងហានិភ័យប្រតិបត្តិការក្នុងការអនុវត្តក្របខ័ណ្ឌភាពគ្រប់គ្រាន់នៃដើមទុន។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា តទៅនេះហៅថា "គ្រឹះស្ថាន"។

គ្រឹះស្ថានត្រូវគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ ទាំងកម្រិតគ្រឹះស្ថាន និងកម្រិតគួបសរុប ប្រសិនបើមាន។ ទម្រង់របាយការណ៍ស្តីពី ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ មានបង្ហាញក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសនេះ។

## ជំពូកទី ២

## អភិបាលកិច្ច

**ប្រការ ៣.- ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ**

ហានិភ័យប្រតិបត្តិការ សំដៅដល់ហានិភ័យដែលកើតឡើងពីភាពមិនគ្រប់គ្រាន់ ឬមានកំហុសឆ្គងនៃកត្តាមួយចំនួន រួមមាន នីតិវិធីផ្ទៃក្នុង មនុស្ស និងប្រព័ន្ធ ឬជាហានិភ័យដែលកើតឡើងពីព្រឹត្តិការណ៍ខាងក្រៅ ដូចជា ហានិភ័យផ្នែកច្បាប់ ប៉ុន្តែមិនរួមបញ្ចូលហានិភ័យយុទ្ធសាស្ត្រ និងហានិភ័យកេរ្តិ៍ឈ្មោះទេ។

គ្រឹះស្ថានត្រូវមានក្របខ័ណ្ឌគ្រប់គ្រងហានិភ័យប្រតិបត្តិការនៅក្នុងគោលនយោបាយនិងដំណើរការគ្រប់គ្រងហានិភ័យរួម ស្របតាមចរិតលក្ខណៈ ភាពស្មុគស្មាញ និងទំហំនៃសកម្មភាពអាជីវកម្ម។

**ប្រការ ៤.- ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលត្រូវបង្កើត អនុម័ត និងពិនិត្យឡើងវិញជាប្រចាំលើក្របខ័ណ្ឌគ្រប់គ្រងហានិភ័យប្រតិបត្តិការ។ ក្រុមប្រឹក្សាភិបាលត្រូវធានាថា គោលនយោបាយ ដំណើរការ និងប្រព័ន្ធត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពដើម្បី កំណត់ វាយតម្លៃ តាមដាន គ្រប់គ្រង និងដោះស្រាយបញ្ហាហានិភ័យប្រតិបត្តិការក្រោមការទទួលខុសត្រូវដោយផ្ទាល់របស់គណៈគ្រប់គ្រងជាន់ខ្ពស់។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់និងអនុម័តរីសអាប់ភៃថាយដែលគ្រឹះស្ថានមានបំណងទទួលយកសម្រាប់ហានិភ័យប្រតិបត្តិការដែលបញ្ជាក់អំពីចរិតលក្ខណៈ ប្រភេទ និងកម្រិតហានិភ័យប្រតិបត្តិការ។

**ប្រការ ៥.- ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងជាន់ខ្ពស់**

គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយ ដំណើរការ និងប្រព័ន្ធសម្រាប់គ្រប់គ្រងហានិភ័យប្រតិបត្តិការ ស្របតាមក្របខ័ណ្ឌហានិភ័យប្រតិបត្តិការដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

គណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវធានាថា គ្រឹះស្ថានមាននីតិវិធីអនុម័តសមស្របមុននឹងដាក់ឱ្យអនុវត្តផលិតផល សេវា សកម្មភាព ដំណើរការ និងប្រព័ន្ធ ថ្មីៗ ដើម្បីអាចវាយតម្លៃហានិភ័យប្រតិបត្តិការបានពេញលេញ។

**ប្រការ ៦.- បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង**

គ្រឹះស្ថានត្រូវមានយន្តការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងដែលរឹងមាំ និងត្រូវអនុវត្តយន្តការនេះស្របតាមក្របខ័ណ្ឌគ្រប់គ្រងហានិភ័យប្រតិបត្តិការរបស់គ្រឹះស្ថាន។

យន្តការគ្រប់គ្រងហានិភ័យបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងរួមមាន ការគ្រប់គ្រងសុវត្ថិភាព ការគ្រប់គ្រងការផ្លាស់ប្តូរនិងការអភិវឌ្ឍប្រព័ន្ធ ដំណើរការព័ត៌មាន បណ្តាញទំនាក់ទំនង និងការគ្រប់គ្រងអ្នកផ្តល់សេវាបច្ចេកវិទ្យា។

**ប្រការ ៧.- យន្តការរាយការណ៍**

គ្រឹះស្ថានត្រូវមានយន្តការរាយការណ៍សមស្របនៅកម្រិតក្រុមប្រឹក្សាភិបាល កម្រិតគណៈគ្រប់គ្រងជាន់ខ្ពស់ និងកម្រិតផ្នែកអាជីវកម្ម ដើម្បីឱ្យការគ្រប់គ្រងហានិភ័យប្រតិបត្តិការមានលក្ខណៈបុរេសកម្ម។

**ប្រការ ៨.- ផែនការនិរន្តរភាពអាជីវកម្ម**

ផែនការនិរន្តរភាពអាជីវកម្ម សំដៅដល់ផែនការដែលកំណត់វិធានការនិងនីតិវិធីចាំបាច់សម្រាប់បន្ត ឬស្តារប្រតិបត្តិការរបស់គ្រឹះស្ថាននៅពេលដែលប្រព័ន្ធប្រើប្រាស់ជាប្រក្រតីមិនដំណើរការ និង/ឬ ក្នុងស្ថានភាពមានអាសន្ន ដូចជា គ្រោះមហន្តរាយ គ្រោះធម្មជាតិ ឬការវាយប្រហារសាយប័រ (Cyber-attacks) ជាដើម។

គ្រឹះស្ថានត្រូវមានផែនការនិរន្តរភាពអាជីវកម្ម ដើម្បីធានាថា គ្រឹះស្ថានមានលទ្ធភាពធ្វើប្រតិបត្តិការជាប្រក្រតីគ្រប់កាលៈទេសៈ និងកាត់បន្ថយការខាតបង់ក្នុងករណីដែលមានការរំខានធ្ងន់ធ្ងរដល់ប្រតិបត្តិការអាជីវកម្ម។

## ជំពូកទី ៣

## វិធីសាស្ត្រគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ

**ប្រការ ៩.- ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ**

គ្រឹះស្ថានត្រូវគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ តាមរូបមន្តដូចខាងក្រោម៖

| ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យ<br>សម្រាប់ហានិភ័យប្រតិបត្តិការ | = | កាតព្វកិច្ចដើមទុនសម្រាប់<br>ហានិភ័យប្រតិបត្តិការ | X ១២,៥០ |
|---|---|---|---|

**ប្រការ ១០.- ការគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យប្រតិបត្តិការ**

គ្រឹះស្ថានត្រូវគណនាកាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យប្រតិបត្តិការ (Operational risk capital requirement - ORC) ដែលស្មើនឹង *សមាសធាតុកត្តាអាជីវកម្ម (Business indicator component - BIC)* គុណជាមួយនឹង *មេគុណការខាតបង់ផ្ទៃក្នុង (Internal loss multiplier - ILM)* ។

រូបមន្ត៖

$$ORC = BIC \times ILM$$

ដែល៖

- BIC = កត្តាអាជីវកម្ម (Business indicator - BI) × មេគុណម៉ាជីណល (Marginal coefficients) ដូចមានកំណត់ក្នុងប្រការ ១១ និង១២ នៃប្រកាសនេះ និង
- ILM = មេគុណការខាតបង់ផ្ទៃក្នុង ដូចមានកំណត់ក្នុងប្រការ ១៣ នៃប្រកាសនេះ។

**ប្រការ ១១.- ការគណនា BIC**

គ្រឹះស្ថានត្រូវគណនា BIC ដែលស្មើនឹង *BI* គុណជាមួយនឹង *មេគុណម៉ាជីណាល*។

គ្រឹះស្ថានត្រូវគណនា BIC តាមមូលដ្ឋានតាមថ្នាក់ (Tiered basis) ដោយផ្អែកលើកម្រិតចន្លោះ BI និងកម្រិតមេគុណម៉ាជីណាលដូចមានក្នុងតារាងខាងក្រោម៖

| កម្រិត | កម្រិតចន្លោះ BI (គិតជាលានរៀល) | មេគុណម៉ាជីណាល |
|---|---|---|
| ១ | ≤ ១៥០.០០០ | ១២% |
| ២ | ១៥០.០០០ < BI ≤ ៣០០.០០០ | ១៥% |
| ៣ | > ៣០០.០០០ | ១៨% |

ធនាគារជាតិនៃកម្ពុជាអាចកែប្រែកម្រិត BI និងកម្រិតមេគុណម៉ាជីណាល ក្នុងតារាងខាងលើស្របតាមការចាំបាច់ និងការវិវត្តនៃប្រព័ន្ធធនាគារនិងស្ថានភាពសេដ្ឋកិច្ច។

**ប្រការ ១២.- ការគណនា BI**

BI របស់គ្រឹះស្ថាន ជាផលបូករវាង៖

- សមាសធាតុការប្រាក់ ភតិសន្យា និងភាគលាភ (Interest, Leases, and Dividend Components - ILDC)
- សមាសធាតុសេវា (Services Component - SC) និង
- សមាសធាតុហិរញ្ញវត្ថុ (Financial Component - FC)។

រូបមន្ត៖

BI = ILDC + SC + FC

ដែល៖

ILDC = អប្បបរមារវាង [តម្លៃដាច់ខាតនៃ (ចំណូលការប្រាក់ – ចំណាយការប្រាក់) និង (២,២៥% x ទ្រព្យសកម្មដែលអាចរកបានចំណូលការប្រាក់ )] + ចំណូលភាគលាភ

មានន័យថាជា {អប្បបរមារវាង [មធ្យមភាគនៃតម្លៃដាច់ខាតនៃ (ចំណូលការប្រាក់ – ចំណាយការប្រាក់)] និង [២,២៥% x មធ្យមភាគនៃទ្រព្យសកម្មដែលអាចរកបានចំណូលការប្រាក់]} + {មធ្យមភាគនៃចំណូលភាគលាភ}

SC = អតិបរមារវាង (ចំណូលប្រតិបត្តិការផ្សេងៗ និង ចំណាយប្រតិបត្តិការផ្សេងៗ) + អតិបរមារវាង (ចំណូលកម្រៃសេវា និង ចំណាយកម្រៃសេវា)

មានន័យថាជា {អតិបរមារវាង [មធ្យមភាគនៃចំណូលប្រតិបត្តិការផ្សេងៗ និង មធ្យមភាគនៃចំណាយប្រតិបត្តិការផ្សេងៗ]} + {អតិបរមារវាង [មធ្យមភាគនៃចំណូលកម្រៃសេវា និង មធ្យមភាគនៃចំណាយកម្រៃសេវា]}

FC = តម្លៃដាច់ខាតនៃ (ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរ) + តម្លៃដាច់ខាតនៃ (ចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ)

មានន័យថាជា (មធ្យមភាគនៃតម្លៃដាច់ខាតនៃចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរ) + (មធ្យមភាគនៃតម្លៃដាច់ខាតនៃចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ)

និង

១. សមាសធាតុនីមួយៗ នៃ BI ត្រូវបានពន្យល់លម្អិតក្នុងឧបសម្ព័ន្ធ ២ នៃប្រកាសនេះ និង

២. ILDC, SC និង FC ត្រូវបានគណនាដូចរូបមន្តខាងលើដែលជាតុនីមួយៗត្រូវគណនាជាមធ្យមរយៈពេល ៣ ឆ្នាំជាប់គ្នា ដោយប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានដែលបានធ្វើសវនកម្មរួច ប្រសិនបើមាន។

ឧទាហរណ៍នៃការគណនា BI មានបង្ហាញក្នុងឧបសម្ព័ន្ធ ៣ នៃប្រកាសនេះ។

**ប្រការ ១៣.- ការគណនា ILM**

សម្រាប់ស្ថានភាពបច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកំណត់ ILM ស្មើ ១។ កម្រិត ILM នេះអាចត្រូវបានកំណត់ឡើងវិញស្របតាមស្ថានភាពហានិភ័យប្រតិបត្តិការ និងអាចកំណត់ធំជាង ១ ចំពោះគ្រឹះស្ថានណាដែលមានហានិភ័យប្រតិបត្តិការខ្ពស់។

គ្រឹះស្ថានត្រូវចងក្រងទិន្នន័យស្តីពីប្រវត្តិ និងសមាសធាតុនៃការខាតបង់ (Loss component) សម្រាប់គោលបំណងគណនា ILM នាពេលអនាគត និងត្រូវបង្ហាញជូនធនាគារជាតិនៃកម្ពុជានៅពេលចាំបាច់។

## ជំពូកទី ៤

## បញ្ញត្តិផ្សេងៗ

**ប្រការ ១៤.- ការគណនា BI ក្នុងករណីគ្រឹះស្ថានមិនមានទិន្នន័យគ្រប់ ៣ ឆ្នាំ**

សម្រាប់គ្រឹះស្ថានដែលមិនមានទិន្នន័យគ្រប់ ៣ ឆ្នាំ ILDC, SC និង FC ត្រូវគណនាស្របតាមរូបមន្តដូចមានកំណត់ក្នុងប្រការ ១២ នៃប្រកាសនេះ ដោយប្រើប្រាស់វិធីសាស្ត្រមូលដ្ឋានប្រចាំឆ្នាំជាតួលេខប៉ាន់ស្មានចំពោះ BI សម្រាប់ឆ្នាំដែលមិនមានទិន្នន័យពេញលេញ។ ការគណនា BI ក្នុងករណីគ្រឹះស្ថានមិនមានទិន្នន័យគ្រប់ ៣ ឆ្នាំ មានបង្ហាញក្នុងឧបសម្ព័ន្ធ ៣ នៃប្រកាសនេះ។

**ប្រការ ១៥.- ការទិញ ឬ លក់អាជីវកម្ម**

នៅពេលគ្រឹះស្ថានទិញ ឬលក់អាជីវកម្ម (មួយផ្នែកឬទាំងមូល) គ្រឹះស្ថានត្រូវពិគ្រោះយោបល់ជាមួយធនាគារជាតិនៃកម្ពុជា ជាមុន ដើម្បីកំណត់កាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យប្រតិបត្តិការ។

**ប្រការ ១៦.- កាតព្វកិច្ចរាយការណ៍**

គ្រឹះស្ថានត្រូវផ្ញើរបាយការណ៍ស្តីពី ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការប្រចាំខែសម្រាប់របាយការណ៍កម្រិតគ្រឹះស្ថាន យ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ នៃខែបន្ទាប់ និងប្រចាំត្រីមាសសម្រាប់កម្រិតគួបសរុប (ប្រសិនបើមាន) យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែទីមួយនៃត្រីមាសបន្ទាប់ មកធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៥

## ទណ្ឌកម្ម និងពិន័យ

**ប្រការ ១៧.- ទណ្ឌកម្មខាងវិន័យ**

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះនឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

### ប្រការ ១៨.- ពិន័យអន្តរការណ៍

បន្ថែមលើទណ្ឌកម្មខាងវិន័យ ធនាគារជាតិនៃកម្ពុជាអាចនឹងដាក់ពិន័យអន្តរការណ៍ដូចខាងក្រោម៖

១. គ្រឹះស្ថានដែលមិនគោរពកាតព្វកិច្ចរាយការណ៍ដូចមានកំណត់ក្នុងប្រការ ១៦ នៃប្រកាសនេះ នឹងត្រូវទទួលរងពិន័យជាទឹកប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ១ (មួយ) ថ្ងៃ។

២. គ្រឹះស្ថានដែលល្មើសនឹងបញ្ញត្តិផ្សេងៗទៀតក្រៅពីចំណុច (១) នៃប្រការនេះ នឹងត្រូវទទួលរងពិន័យជាទឹកប្រាក់ ចំនួន ៣.០០០.០០០ (បីលាន) រៀល ក្នុង ១ (មួយ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលធនាគារជាតិនៃកម្ពុជាអនុញ្ញាតឱ្យកែតម្រូវផុតកំណត់។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

### ប្រការ ១៩.- ការអនុវត្ត

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គនាយកប្រតិបត្តិការ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

### ប្រការ ២០.- ថ្ងៃប្រសិទ្ធភាព

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤

**ទេសាភិបាល**

ជា សិរី

**កន្លែងទទួល៖**

- ដូចប្រការ ១៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

# ឧបសម្ព័ន្ធ ១

## របាយការណ៍ប្រចាំខែ/ត្រីមាស ស្តីពី ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ

## Monthly/Quarterly Report on Risk-Weighted Assets ( RWA ) for Operational Risk in Deposit-taking Banks and Financial Institutions

លេខសម្គាល់របាយការណ៍
Report ID

ជំនាន់របាយការណ៍
Report Version

កាលបរិច្ឆេទ
As at

ឈ្មោះគ្រឹះស្ថាន
Institution's Name

អត្រាប្តូរប្រាក់ក្នុង ១ ដុល្លារអាមេរិក = X រៀល
Exchange Rate 1 USD = X Riel

ឯកតាគិតជាលានរៀល
In million Riels

| ខ្ទង់<br>Items | ឆ្នាំ–២<br>T–2 | ឆ្នាំ–១<br>T–1 | ឆ្នាំ<br>T | ជាមធ្យម<br>Average |
|---|---|---|---|---|
| **១. សមាសធាតុការប្រាក់ ភតិសន្យា និងភាគលាភ**<br>**1. Interest, Leases and Dividend Component (ILDC)** | | | | |
| ចំណូលការប្រាក់<br>Interest income | | | | |
| ចំណាយការប្រាក់<br>Interest expense | | | | |
| តម្លៃដាច់ខាតនៃ (ចំណូលការប្រាក់ – ចំណាយការប្រាក់)<br>Abs (Interest income – Interest expense) | | | | |
| ទ្រព្យសកម្មដែលអាចរកបានចំណូលការប្រាក់<br>Interest earning assets | | | | |
| ចំណូលភាគលាភ<br>Dividend income | | | | |



៤

| | | | | |
|---|---|---|---|---|
| **២. សមាសធាតុសេវា**<br>**2. Service Component (SC)** | | | | |
| ចំណូលប្រតិបត្តិការផ្សេងៗ<br>Other operating income | | | | |
| ចំណាយប្រតិបត្តិការផ្សេងៗ<br>Other operating expense | | | | |
| ចំណូលកម្រៃសេវា<br>Fee income | | | | |
| ចំណាយកម្រៃសេវា<br>Fee expense | | | | |
| **៣. សមាសធាតុហិរញ្ញវត្ថុ**<br>**3. Financial Component (FC)** | | | | |
| ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរ<br>Net P&L trading book | | | | |
| ចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ<br>Net P&L banking book | | | | |
| **៤. កត្តាអាជីវកម្ម (៤) = (១) + (២) + (៣)**<br>**4. Business Indicator (BI) (4) = (1) + (2) + (3)** | | | | |
| **៥. សមាសធាតុកត្តាអាជីវកម្ម (៥) = (៤) x មេគុណម៉ាជីណល**<br>**5. Business Indicator Component (BIC) (5) = (4) x Marginal coefficients** | | | | |
| **៦. មេគុណការខាតបង់ផ្ទៃក្នុង**<br>**6. Internal Loss Multiplier (ILM)** | | | | ១ |
| **៧. តម្រូវការដើមទុនសម្រាប់ហានិភ័យប្រតិបត្តិការ (៧) = (៥) x (៦)**<br>**7. Operational Risk Capital Requirement (ORC) (7) = (5) x (6)** | | | | |
| **៨. ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ (៨) = (៧) x ១២,៥០**<br>**8. RWA for Operational Risk (8) = (7) x 12.50** | | | | |

បញ្ជាក់៖ គ្រប់ Row និង Column ទាំងអស់ត្រូវបំពេញលេខ ឬយ៉ាងហោចណាស់លេខសូន្យ (0) និងមិនអនុញ្ញាតឱ្យបំពេញលេខអវិជ្ជមានទេ។

# ឧបសម្ព័ន្ធ ២

## សមាសធាតុនីមួយៗ នៃ BI

### តារាងទី១៖ ILDC

| ខ្ទង់ | បរិយាយ | ឧទាហរណ៍ |
|---|---|---|
| ចំណូលការប្រាក់ (ខ្ទង់ក្នុងរបាយការណ៍ចំណេញ-ខាត) | ចំណូលការប្រាក់ដែលទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ និងចំណូលការប្រាក់ផ្សេងទៀត (រួមមានចំណូលការប្រាក់ពីភតិសន្យាហិរញ្ញវត្ថុ និងភតិសន្យាប្រតិបត្តិការ និងចំណេញពីទ្រព្យសកម្មភតិសន្យា)។ | - ចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ការវិនិយោគនិងមូលបត្រជួញដូរ ភតិសន្យាហិរញ្ញវត្ថុ និងភតិសន្យាប្រតិបត្តិការ<br>- ចំណូលការប្រាក់ពីឧបករណ៍និស្សន្ទនៃគណនេយ្យការពារលើហានិភ័យ (Hedge accounting)<br>- ចំណូលការប្រាក់ផ្សេងៗ<br>- ចំណេញពីទ្រព្យសកម្មភតិសន្យា |
| ចំណាយការប្រាក់ (ខ្ទង់ក្នុងរបាយការណ៍ចំណេញ-ខាត) | ចំណាយការប្រាក់ពីទ្រព្យអកម្មហិរញ្ញវត្ថុទាំងអស់ និងចំណាយការប្រាក់ផ្សេងទៀត (រួមមាន ចំណាយការប្រាក់លើភតិសន្យាហិរញ្ញវត្ថុ និងភតិសន្យាប្រតិបត្តិការ រំលស់ ការធ្វើអ៊ីមភែរមិន និងការខាតបង់ពីទ្រព្យសកម្មភតិសន្យាប្រតិបត្តិការ)។ | - ចំណាយការប្រាក់លើប្រាក់បញ្ញើ មូលបត្របំណុលដែលបានបោះផ្សាយ ភតិសន្យាហិរញ្ញវត្ថុ និងភតិសន្យាប្រតិបត្តិការ<br>- ចំណាយការប្រាក់ពីឧបករណ៍និស្សន្ទនៃគណនេយ្យការពារលើហានិភ័យ (Hedge accounting)<br>- ចំណាយការប្រាក់ផ្សេងៗ<br>- ការខាតបង់ពីទ្រព្យសកម្មភតិសន្យា<br>- រំលស់ និងអ៊ីមភែរមិននៃទ្រព្យសកម្មភតិសន្យាប្រតិបត្តិការ |
| ទ្រព្យសកម្មដែលអាចរកបានចំណូលការប្រាក់ (ខ្ទង់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ឬរបាយការណ៍គំលាតវេទយិតភាពការប្រាក់) | សមតុល្យដុលសរុបនៃ ឥណទាន បុរេប្រទាន មូលបត្រដែលមានការប្រាក់ (ដូចជាមូលបត្ររដ្ឋ) និងទ្រព្យសកម្មភតិសន្យាដែលត្រូវបានវាស់វែងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ។ | |
| ចំណូលភាគលាភ (ខ្ទង់ក្នុងរបាយការណ៍ចំណេញ-ខាត) | ចំណូលភាគលាភដែលទទួលបានពីការវិនិយោគលើភាគហ៊ុន និងមូលនិធិ ដែលមិនបានរាយការណ៍ក្នុងរបាយការណ៍ហិរញ្ញវត្ថុគួបសរុបរបស់គ្រឹះស្ថាន រួមមានចំណូលភាគលាភពីក្រុមហ៊ុនបុត្តសម្ព័ន្ធ និងសមាគារី (Associates) ដែលមិនបានគួបសរុប និងក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា (Joint ventures)។ | |

### តារាងទី២៖ SC

| ខ្ទង់ | បរិយាយ | ឧទាហរណ៍ |
|---|---|---|
| ចំណូលកម្រៃសេវា (ខ្ទង់ក្នុងរបាយការណ៍ចំណេញ-ខាត) | ប្រាក់ចំណូលដែលទទួលបានពីសេវាផ្តល់យោបល់និងសេវាផ្សេងៗ រួមបញ្ចូលប្រាក់ចំណូលដែលគ្រឹះស្ថានទទួលបានពីការផ្តល់សេវាហិរញ្ញវត្ថុជាតតិយភាគី (Outsourcer of financial services) និងអាជីវកម្មប៊េងកាសួរេន (Bancassurance business)។ | សោហ៊ុយនិងកម្រៃជើងសាទទួលបានពី៖<br>- មូលបត្រ (ការបោះផ្សាយ ប្រតិបត្តិការតាមការបញ្ជារបស់អតិថិជន)<br>- ការផាត់ទាត់និងការទូទាត់, ការគ្រប់គ្រងទ្រព្យសកម្ម, សេវារក្សាទុក, ប្រតិបត្តិការបរធនបាលកិច្ច (Trust transaction), សេវាទូទាត់, ស៊ីខ្សែរីថាយសេសិន, កិច្ចសន្យាឱ្យខ្ចីនិងកិច្ចសន្យាធានា, និងប្រតិបត្តិការដែលធ្វើឡើងនៅបរទេស |
| ចំណាយកម្រៃសេវា (ខ្ទង់ក្នុងរបាយការណ៍ចំណេញ-ខាត) | ចំណាយដែលបានទូទាត់លើការប្រើប្រាស់សេវាផ្តល់យោបល់ និងសេវាផ្សេងៗ រួមបញ្ចូលចំណាយកម្រៃសេវាតតិយភាគី (Outsourcing fee) ប៉ុន្តែមិនគិតបញ្ចូលចំណាយកម្រៃតតិយភាគីចំពោះសេវាមិនមែនហិរញ្ញវត្ថុ ដូចជាសម្រាប់ការផ្គត់ផ្គង់សេវាមិនមែនហិរញ្ញវត្ថុ (ឡូជីស្ទីក បច្ចេកវិទ្យាព័ត៌មាន និងធនធានមនុស្ស)។ | ចំណាយសោហ៊ុយ និងកម្រៃជើងសាលើសេវាផាត់ទាត់និងទូទាត់, សេវារក្សាទុក, សេវាពាក់ព័ន្ធនឹងស៊ីខ្សែរីថាយសេសិន, កិច្ចសន្យាឱ្យខ្ចីនិងកិច្ចសន្យាធានា និងប្រតិបត្តិការដែលធ្វើឡើងនៅបរទេស |
| ចំណូលប្រតិបត្តិការផ្សេងៗ (ខ្ទង់ក្នុងរបាយការណ៍ចំណេញ-ខាត) | ប្រាក់ចំណូលទទួលបានពីប្រតិបត្តិការធនាគារជាប្រក្រតី ដែលមិនត្រូវបានរាប់បញ្ចូលនៅក្នុងតារាងទី១៖ ILDC និងខ្ទង់នៃតារាងទី២៖ SC ខាងលើ ប៉ុន្តែមានលក្ខណៈស្រដៀងគ្នានឹងខ្ទង់ទាំងនេះ (ចំណូលពីភតិសន្យាប្រតិបត្តិការត្រូវតែដកចេញដោយសារចំណូលនេះត្រូវបានគិតបញ្ចូលក្នុងតារាងទី១៖ ILDC រួចហើយ)។ | - ចំណូលពីការជួលអចលនទ្រព្យវិនិយោគ<br>- ចំណេញពីទ្រព្យសកម្មរយៈពេលវែង និងក្រុមទ្រព្យសកម្មត្រូវលក់ដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរក្សាទុកសម្រាប់លក់ ប៉ុន្តែមិនបំពេញលក្ខណៈវិនិច្ឆ័យជាកិច្ចប្រតិបត្តិការមិនបន្ត (ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា - ស.រ.ហ.អ.ក ៥-៣៧) |
| ចំណាយប្រតិបត្តិការផ្សេងៗ (ខ្ទង់ក្នុងរបាយការណ៍ចំណេញ-ខាត) | ចំណាយនិងការខាតបង់ពីប្រតិបត្តិការធនាគារជាប្រក្រតី ដែលមិនត្រូវបានរាប់បញ្ចូលនៅក្នុងតារាងទី១៖ ILDC និងខ្ទង់នៃតារាងទី២៖ SC ខាងលើ ប៉ុន្តែមានលក្ខណៈស្រដៀងគ្នានឹងខ្ទង់ទាំងនេះ (ចំណាយពីភតិសន្យាប្រតិបត្តិការត្រូវ | - ខាតពីទ្រព្យសកម្មរយៈពេលវែងនិងក្រុមទ្រព្យសកម្មត្រូវលក់ដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរក្សាទុកសម្រាប់លក់ ប៉ុន្តែមិនបំពេញលក្ខណៈវិនិច្ឆ័យជាកិច្ចប្រតិបត្តិការមិនបន្ត (ស.រ.ហ.អ.ក ៥-៣៧) |

| | | |
|---|---|---|
| | ដកចេញដោយសារចំណាយនេះត្រូវបានគិតបញ្ចូលក្នុងតារាងទី១៖ ILDC រួចហើយ)។ | - ខាតដែលកើតឡើងពីហានិភ័យប្រតិបត្តិការ (ឧទាហរណ៍ ការផាកពិន័យ ការទូទាត់ ចំណាយក្នុងការផ្លាស់ប្តូរទ្រព្យសកម្មដែលខូចខាត) ដែលមិនបានធ្វើសំវិធានធនឬបម្រុងទុកពីឆ្នាំមុនៗ<br>- ចំណាយទាក់ទងនឹងការធ្វើសំវិធានធនឬបម្រុងទុកសម្រាប់ហានិភ័យប្រតិបត្តិការ |

**តារាងទី៣៖ FC**

| **ខ្ទង់** | **ឧទាហរណ៍** |
|---|---|
| ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរ (ខ្ទង់ក្នុងរបាយការណ៍ចំណេញ-ខាត) | - ចំណេញ/ខាតសុទ្ធលើទ្រព្យសកម្មនិងទ្រព្យអកម្មសម្រាប់ជួញដូរ (ឧបករណ៍និស្សន្ទ មូលបត្របំណុល មូលបត្រកម្មសិទ្ធិ ឥណទាននិងបុរេប្រទានសតប៉ូស៊ីសិន ទ្រព្យសកម្មនិងទ្រព្យអកម្មផ្សេងទៀត)<br>- ចំណេញ/ខាតសុទ្ធលើគណនេយ្យការពារលើហានិភ័យ (Hedge accounting)<br>- ចំណេញ/ខាតសុទ្ធលើលម្អៀងពីការផ្លាស់ប្តូររូបិយប័ណ្ណ |
| ចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ (ខ្ទង់ក្នុងរបាយការណ៍ចំណេញ-ខាត) | - ចំណេញ/ខាតសុទ្ធលើទ្រព្យសកម្មនិងទ្រព្យអកម្មហិរញ្ញវត្ថុកំណត់តាមតម្លៃសមស្របតាមចំណេញ-ខាត<br>- ចំណេញ/ខាតពិតលើទ្រព្យសកម្មនិងទ្រព្យអកម្មហិរញ្ញវត្ថុដែលមិនកំណត់តាមតម្លៃសមស្របតាមចំណេញ-ខាត (ឥណទាននិងបុរេប្រទាន ការវិនិយោគនិងមូលបត្រជួញដូរ និងទ្រព្យអកម្មហិរញ្ញវត្ថុកំណត់តាមរំលស់ថ្លៃដើម)<br>- ចំណេញ/ខាតសុទ្ធលើគណនេយ្យការពារលើហានិភ័យ (Hedge accounting)<br>- ចំណេញ/ខាតសុទ្ធលើលម្អៀងពីការផ្លាស់ប្តូររូបិយប័ណ្ណ |

**គ្រឹះស្ថានមិនត្រូវរាប់បញ្ចូលក្នុងការគណនា BI នូវខ្ទង់មួយចំនួនដូចខាងក្រោម៖**

(ក) ចំណាយរដ្ឋបាល រួមបញ្ចូលទាំងចំណាយលើប្រាក់បៀវត្សរ៍ឬប្រាក់ឈ្នួលនិងអត្ថប្រយោជន៍បុគ្គលិក ចំណាយកម្រៃតតិយភាគីចំពោះសេវាមិនមែនហិរញ្ញវត្ថុ (ដូចជា ឡូជីស្ទីក ធនធានមនុស្ស បច្ចេកវិទ្យាព័ត៌មាន ជាដើម) និងការចំណាយរដ្ឋបាលផ្សេងទៀត (ដូចជា បច្ចេកវិទ្យាព័ត៌មាន ថ្លៃទឹក ថ្លៃភ្លើង ទូរស័ព្ទ ការធ្វើដំណើរ សម្ភារៈបរិក្ខារការិយាល័យ ប្រៃសណីយ៍ ជាដើម)

(ខ) ការប្រមូលបានមកវិញនូវចំណាយរដ្ឋបាល ដូចជា ការប្រមូលបានមកវិញនូវការទូទាត់តាមការបញ្ជារបស់អតិថិជន (ឧទាហរណ៍ ពន្ធដែលបានកាត់ចេញពីអតិថិជន)

(គ) ចំណាយលើអគារ និងអចលនទ្រព្យ (លើកលែងតែចំណាយនៃការខាតបង់ពីហានិភ័យប្រតិបត្តិការ)

(ឃ) ចំណាយរំលស់លើទ្រព្យសកម្មរូបី និងអរូបី (លើកលែងរំលស់ដែលពាក់ព័ន្ធនឹងទ្រព្យសកម្មភតិសន្យាប្រតិបត្តិការដែលទ្រព្យសកម្មនេះត្រូវគិតបញ្ចូលក្នុងខ្ទង់ចំណាយភតិសន្យាហិរញ្ញវត្ថុ និងភតិសន្យាប្រតិបត្តិការ)

(ង) សំវិធានធន ឬសំវិធានធនត្រឡប់ (Reversal of provision) (ដូចជា ទៅលើប្រាក់សោធនការសន្យា (Commitment) និងការធានា) លើកលែងតែសំវិធានធនពាក់ព័ន្ធនឹងការខាតបង់នៃហានិភ័យប្រតិបត្តិការ

(ច) ចំណាយនៃដើមទុនភាគហ៊ុនសងតាមតម្រូវការ

(ឆ) *អ៊ីមភែរមិន* ឬ *អ៊ីមភែរមិន*ត្រឡប់ (Reversal of impairment) (ដូចជា ទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ការវិនិយោគទៅក្នុងបុត្តសម្ព័ន្ធ ក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា (Joint ventures) និងសមាការី (Associates))

(ជ) ការប្រែប្រួលតម្លៃកេរ្តិ៍ឈ្មោះដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ ស្តីពី ចំណេញ-ខាត និង

(ឈ) ពន្ធលើប្រាក់ចំណូលសាជីវកម្ម (ពន្ធផ្អែកលើប្រាក់ចំណេញ រួមទាំងពន្ធក្នុងគ្រានិងពន្ធពន្យារ)។

# ឧបសម្ព័ន្ធ ៣

## ការគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ

### ក- ការគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការក្នុងករណីគ្រឹះស្ថានមានទិន្នន័យគ្រប់ ៣ ឆ្នាំ

ដើម្បីគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ គ្រឹះស្ថានត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

**ជំហានទី១៖** គណនា BI

**ជំហានទី២៖** គណនា BIC

**ជំហានទី៣៖** គណនា ORC និង

**ជំហានទី៤៖** គណនា RWA

ឧទាហរណ៍៖ គ្រឹះស្ថានមានទិន្នន័យដែលដកស្រង់ពីរបាយការណ៍ស្តីពី ចំណេញ-ខាត ដូចខាងក្រោម៖

គិតជាលានរៀល

| ខ្ទង់ | ឆ្នាំ ២០២១ | ឆ្នាំ ២០២២ | ឆ្នាំ ២០២៣ |
|---|---|---|---|
| **១ ចំណូលការប្រាក់** | **៣០០.០០០** | **៥០០.០០០** | **៧០០.០០០** |
| **២ ចំណាយការប្រាក់** | **១៨០.០០០** | **១៦០.០០០** | **២២០.០០០** |
| **៣ ចំណូលសុទ្ធពីការប្រាក់** | **១២០.០០០** | **៣៤០.០០០** | **៤៨០.០០០** |
| **៤ ចំណូលមិនមែនការប្រាក់** | **១៦២.២៩៥** | **១៨៨.៨៦៣** | **២១៣.៤៦៦** |
| ៤.១ ចំណូលភាគលាភ | ៤៧៥ | ៤៨៣ | ១.៦៦៦ |
| ៤.២ ចំណេញ/ខាតពីប្រតិបត្តិការហិរញ្ញវត្ថុ | ៨២០ | ១.៣៨០ | ១.៨០០ |
| ៤.២.១ ការវាយតម្លៃប្រចាំខែ និងការលក់មូលបត្រ | ១០០ | ១៨០ | ២៧០ |
| ៤.២.១.១ ចំណេញ | ២០០ | ២៣០ | ៣៧០ |
| ៤.២.១.២ ចំណាយដែលកើតមាន | ១០០ | ៥០ | ១០០ |
| ៤.២.២ ចំណេញ/ខាតសុទ្ធពីជំនួញប្តូរប្រាក់ | ៥០០ | ៨០០ | ១.០០០ |
| ៤.២.៣ ប្រតិបត្តិការឧបករណ៍និស្សន្ទ | ២០០ | ៣៥០ | ៤៥០ |
| ៤.២.៤ ផ្សេងៗ | ២០ | ៥០ | ៨០ |
| ៤.៣ កម្រៃជើងសា និងសោហ៊ុយ | ១៣១.០០០ | ១៣៧.០០០ | ១៤០.០០០ |
| ៤.៣.១ ចំណូល | ១៣៦.០០០ | ១៤៣.០០០ | ១៤៩.០០០ |
| ៤.៣.២ ចំណាយដែលកើតមាន | ៥.០០០ | ៦.០០០ | ៩.០០០ |
| ៤.៤ ចំណូលមិនមែនប្រតិបត្តិការធនាគារ | ៣០.០០០ | ៥០.០០០ | ៧០.០០០ |
| ៤.៤.១ ក្នុងនោះទទួលបានពីការជួល | ១០.០០០ | ២០.០០០ | ៣០.០០០ |
| **៥ ចំណេញ/ខាត ប្រតិបត្តិការជួល** | **២៨២.២៩៥** | **៥២៨.៨៦៣** | **៦៩៣.៤៦៦** |
| **៦ ចំណាយប្រតិបត្តិការ** | **១៦៨.០០៨** | **២០៤.៦៤១** | **២៥៨.១២៣** |
| ៦.១ បៀវត្សរ៍ និងប្រាក់ឈ្នួល | ៤០.០០០ | ៦០.០០០ | ១០០.០០០ |

| | | | |
|---|---|---|---|
| ៦.២ តម្លៃឈ្នួល និងអត្ថប្រយោជន៍ និយោជិត និង នាយក | ៥០០ | ១.០០០ | ២.០០០ |
| ៦.៣ ការជួល និងភតិសន្យាដែលបានសង | ៤៣.៦៦៧ | ៤៨.២៧៩ | ៤៩.៤៧៥ |
| ៦.៣.១ ចំណាយរំលស់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | ៤២.៣១៩ | ៤៥.៩៨៣ | ៤៨.០២៣ |
| ៦.៣.២ ចំណាយទាក់ទងនឹងភតិសន្យារយៈពេលខ្លី | ១១ | ១៥ | ២០ |
| ៦.៣.៣ ចំណាយទាក់ទងនឹងភតិសន្យាដែលមានតម្លៃទាប | ៣៩ | ៥០ | ៨០ |
| ៦.៣.៤ ចំណាយទាក់ទងនឹងភតិសន្យាដែលមានការទូទាត់ប្រែប្រួល | ៦៩ | ១០៧ | ១១៨ |
| ៦.៣.៥ ចំណាយការជួលផ្សេងៗ | ៨២៩ | ២.១២៤ | ១.២៣៤ |
| ៦.៤ ពន្ធអាករ ថ្លៃអាជ្ញាបណ្ណ និងផាកពិន័យ | ៤.៥៤១ | ៧.២៧២ | ៧.១៩៨ |
| ៦.៤.១ ពន្ធអាករ | ១៥០ | ១.០០០ | ២.៥០០ |
| ៦.៤.២ ថ្លៃអាជ្ញាបណ្ណ និងផាកពិន័យ | ៤.៣៩១ | ៦.២៧២ | ៤.៦៩៨ |
| ៦.៥ ចំណាយលើអាគារ ព្រមទាំងរំលស់ | ២៥០ | ៣៩០ | ៤៥០ |
| ៦.៦ ចំណាយលើសម្ភារៈ | ៣៥០ | ៥០០ | ៦៥០ |
| ៦.៧ ចំណាយលើរំលស់លើទ្រព្យអរូបី | ១០០ | ២០០ | ៣៥០ |
| ៦.៨ ចំណាយប្រតិបត្តិការផ្សេង | ៧៩.០០០ | ៨៧.០០០ | ៩៨.០០០ |
| ៦.៨.១ ពីប្រតិបត្តិការធនាគារ | ៦០.០០០ | ៧៦.០០០ | ៨៣.០០០ |
| ៦.៨.២ មិនមែនពីប្រតិបត្តិការធនាគារ | ១៩.០០០ | ១១.០០០ | ១៥.០០០ |
| **៧ ចំណេញ/ខាត សុទ្ធពីប្រតិបត្តិការ** | **១១៤.២៨៧** | **៣២៤.២២២** | **៤៣៥.៣៤៣** |
| **៨ ខាត/ចំណេញពីចំណាយធ្វើសំវិធានធន និងការប្រមូលបានមកវិញ** | **(៥.៦៣៥)** | **(៣.១៩៤)** | **(៤.១៣៨)** |
| ៨.១ ការខាតបង់ឥណទានរំពឹងទុក - ប្រាក់ដើម | (៥.៥៦៦) | (៣.២៤០) | (៥.១៩៤) |
| ៨.២ ការខាតបង់ឥណទានរំពឹងទុក - ការប្រាក់ | - | (១១) | - |
| ៨.៣ ការខាតបង់ឥណទានរំពឹងទុក - ខ្ទង់ក្រៅតារាងតុល្យការ | (១១៤) | ៨២ | ២៧៥ |
| ៨.៤ ការប្រមូលបានមកវិញ | ៤៥ | ២៥ | ៧៣១ |
| **៩ ការខាតបង់ឥណទានរំពឹងទុកចំពោះមូលបត្រនិងការបាត់បង់ពីការលុបភាគកម្មនៃសិទ្ធិចូលរួម** | **-** | **-** | **-** |
| **១០ ដើមទុនចំណេញ/ខាត ពីទ្រព្យសកម្មដែលមិនអាចប្រើប្រាស់បាន** | **៦៧** | **(៤១)** | **១៥៣** |
| **១១ ចំណេញ/ខាត មុនធ្វើជំពូកអញ្ញាតិកម្ម** | **១០៨.៧១៩** | **៣២១.០៣៧** | **៤៣១.៣៥៨** |
| **១២ ខ្ទង់អញ្ញាតិកម្មផ្សេងៗ** | **(៣០)** | **១០** | **-** |
| ១២.១ ចំណេញធ្វើអញ្ញាតិកម្ម | ១០ | - | - |
| ១២.២ ខាតធ្វើអញ្ញាតិកម្ម | - | - | - |
| ១២.៣ ចំណេញ/ខាត សុទ្ធពីការបង្វែររូបិយប័ណ្ណបរទេស | (៤០) | ១០ | - |

| | | | |
|---|---|---|---|
| **១៣ ចំណេញ/ខាត សុទ្ធមុនបង់ពន្ធ** | **១០៨.៦៨៩** | **៣២១.០៤៧** | **៤៣១.៣៥៨** |
| **១៤ ពន្ធលើប្រាក់ចំណេញ** | **២១.៧៣៨** | **៦៤.២០៩** | **៨៦.២៧២** |
| **១៥ ចំណេញ/ខាត សុទ្ធក្នុងគ្រានេះ** | **៨៦.៩៥១** | **២៥៦.៨៣៨** | **៣៤៥.០៨៦** |
| **១៦ បង្គរចំណេញ/ខាត ពីដើមឆ្នាំមុននឹងបែងចែកប្រាក់ចំណេញ** | **១៨០** | **-** | **២៩០** |
| **១៧ ផ្ទេរទៅទុនបម្រុង** | **-** | **-** | **១២** |
| **១៨ ភាគលាភ** | **៣៩** | **៤៥** | **៥០** |
| **១៩ ផ្ទេរទៅទីស្នាក់ការកណ្តាលនៅ...(បង្ហាញប្រទេស)** | **-** | **-** | **-** |
| **២០ បង្គរចំណេញ/ខាត ពីបណ្តាឆ្នាំមុនបន្ទាប់ពីបែងចែកប្រាក់ចំណេញ** | **៨៧.០៩២** | **២៥៦.៧៩៣** | **៣៤៥.៣១៤** |

គ្រឹះស្ថានត្រូវគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការសម្រាប់របាយការណ៍ខែមករា ឆ្នាំ២០២៤ ដូចខាងក្រោម៖

**ជំហានទី១៖ គណនា BI**

BI = ILDC + SC + FC

**១- ILDC**

គិតជាលានរៀល

| ខ្ទង់ | ឆ្នាំ ២០២១ | ឆ្នាំ ២០២២ | ឆ្នាំ ២០២៣ | ជាមធ្យម |
|---|---|---|---|---|
| ចំណូលការប្រាក់ | ៣០០.០០០ | ៥០០.០០០ | ៧០០.០០០ | |
| ចំណាយការប្រាក់ [១] | ២២២.៤៣៨ | ២០៦.១៥៥ | ២៦៨.២៤១ | |
| តម្លៃដាច់ខាតនៃ (ចំណូលការប្រាក់ – ចំណាយការប្រាក់) | ៧៧.៥៦២ | ២៩៣.៨៤៥ | ៤៣១.៧៥៩ | ២៦៧.៧២២ |
| ទ្រព្យសកម្មដែលអាចរកបានចំណូលការប្រាក់ | ២៥.៨៦០.០០០ | ២៨.៨៩៤.០០០ | ៣២.៣៧៣.០០០ | ២៩.០៤២.៣៣៣ |
| ចំណូលភាគលាភ | ៤៧៥ | ៤៨៣ | ១.៦៦៦ | ៨៧៥ |

[១] ចំណាយការប្រាក់ ដែលស្ថិតក្នុង ខ្ទង់ ២ ចំណាយការប្រាក់ និង ខ្ទង់ ៦.៣ ការជួល និងភតិសន្យាដែលបានសង ប៉ុន្តែមិនបញ្ចូល ខ្ទង់៦.៣.៥ ចំណាយការជួលផ្សេងៗ (ទិន្នន័យដកស្រង់ពីរបាយការណ៍ស្តីពី ចំណេញ-ខាត)

ILDC = អប្បបរមារវាង [ $\overline{\text{តម្លៃដាច់ខាតនៃ (ចំណូលការប្រាក់ – ចំណាយការប្រាក់)}}$ និង (២,២៥% x $\overline{\text{ទ្រព្យសកម្មដែលអាចរកបានចំណូលការប្រាក់}}$ )] + $\overline{\text{ចំណូលភាគលាភ}}$

= អប្បបរមារវាង [២៦៧.៧២២ លានរៀល និង (២,២៥% x ២៩.០៤២.៣៣៣ លានរៀល)] + ៨៧៥ លានរៀល

= អប្បបរមារវាង (២៦៧.៧២២ លានរៀល និង ៦៥៣.៤៥២ លានរៀល) + ៨៧៥ លានរៀល

= ២៦៧.៧២២ លានរៀល + ៨៧៥ លានរៀល

= ២៦៨.៥៩៧ លានរៀល



५

## ២- SC

គិតជាលានរៀល

| ខ្ទង់ | ឆ្នាំ ២០២១ | ឆ្នាំ ២០២២ | ឆ្នាំ ២០២៣ | ជាមធ្យម |
|---|---|---|---|---|
| ចំណូលប្រតិបត្តិការផ្សេងៗ [២] | ៣០.០០០ | ៥០.០០០ | ៧០.០០០ | ៥០.០០០ |
| ចំណាយប្រតិបត្តិការផ្សេងៗ [៣] | ៦៤.៣៩១ | ៨២.២៧២ | ៨៧.៦៩៨ | ៧៨.១២០ |
| ចំណូលកម្រៃសេវា | ១៣៦.០០០ | ១៤៣.០០០ | ១៤៩.០០០ | ១៤២.៦៦៧ |
| ចំណាយកម្រៃសេវា | ៥.០០០ | ៦.០០០ | ៩.០០០ | ៦.៦៦៧ |

[២] ចំណូលប្រតិបត្តិការផ្សេងៗ ដែលស្ថិតក្នុង ខ្ទង់ ៤.៤ ចំណូលមិនមែនប្រតិបត្តិការធនាគារ (ទិន្នន័យដកស្រង់ពីរបាយការណ៍ ស្តីពី ចំណេញ-ខាត)

[៣] ចំណាយប្រតិបត្តិការផ្សេងៗ ដែលស្ថិតក្នុង ខ្ទង់ ៦.៨ ចំណាយប្រតិបត្តិការផ្សេង និងខ្ទង់ ៦.៤.២ ថ្លៃអាជ្ញាបណ្ណ និងផាកពិន័យ (ទិន្នន័យដកស្រង់ពីរបាយការណ៍ស្តីពី ចំណេញ-ខាត)

SC = អតិបរមារវាង ($\overline{\text{ចំណូលប្រតិបត្តិការផ្សេងៗ}}$ និង $\overline{\text{ចំណាយប្រតិបត្តិការផ្សេងៗ}}$) + អតិបរមារវាង ($\overline{\text{ចំណូលកម្រៃសេវា}}$ និង $\overline{\text{ចំណាយកម្រៃសេវា}}$)

= អតិបរមារវាង (៥០.០០០ លានរៀល និង ៧៨.១២០ លានរៀល) + អតិបរមារវាង (១៤២.៦៦៧ លានរៀល និង ៦.៦៦៧ លានរៀល)

= ៧៨.១២០ លានរៀល + ១៤២.៦៦៧ លានរៀល

= ២២០.៧៨៧ លានរៀល

## ៣- FC

គិតជាលានរៀល

| ខ្ទង់ | ឆ្នាំ ២០២១ | ឆ្នាំ ២០២២ | ឆ្នាំ ២០២៣ | ជាមធ្យម |
|---|---|---|---|---|
| តម្លៃដាច់ខាតនៃ (ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរ) +តម្លៃដាច់ខាតនៃ (ចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ) [៤] | ៨២០ | ១.៣៨០ | ១.៨០០ | ១.៣៣៣ |

[៤] ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរនិងចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ ដែលស្ថិតក្នុង ខ្ទង់ ៤.២ ចំណេញ/ខាតពីប្រតិបត្តិការហិរញ្ញវត្ថុ (ទិន្នន័យដកស្រង់ពីរបាយការណ៍ស្តីពី ចំណេញ-ខាត)

FC = $\overline{\text{តម្លៃដាច់ខាតនៃ (ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរ)}}$ + $\overline{\text{តម្លៃដាច់ខាតនៃ (ចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ)}}$

= ១.៣៣៣ លានរៀល

ជាលទ្ធផល BI = ILDC + SC + FC

= ២៦៨.៥៩៧ លានរៀល + ២២០.៧៨៧ លានរៀល + ១.៣៣៣ លានរៀល

BI = ៤៩០.៧១៧ លានរៀល

**ជំហានទី២៖ គណនា BIC**

BIC = BI x មេគុណម៉ាជីណាល

ដោយ BI ក្នុងជំហានទី១ ស្មើនឹង ៤៩០.៧១៧ លានរៀល គ្រឹះស្ថានត្រូវគណនា BIC តាមមូលដ្ឋានតាមថ្នាក់ ដោយប្រើប្រាស់កម្រិតចន្លោះ BI និងមេគុណម៉ាជីណាល ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

គិតជាលានរៀល

| **កម្រិតចន្លោះ BI និងមេគុណម៉ាជីណាល** | | | | **BIC** |
|---|---|---|---|---|
| **កម្រិត** | **កម្រិតចន្លោះ BI** | **BI** | **មេគុណម៉ាជីណាល** | |
| ១ | ≤ ១៥០.០០០ | ១៥០.០០០ | ១២% | ១៨.០០០ |
| ២ | ១៥០.០០០ < BI ≤ ៣០០.០០០ | ១៥០.០០០ | ១៥% | ២២.៥០០ |
| ៣ | > ៣០០.០០០ | ១៩០.៧១៧ | ១៨% | ៣៤.៣២៩ |
| **សរុប** | | **៤៩០.៧១៧** | | **៧៤.៨២៩** |

**ជំហានទី៣៖ គណនា ORC**

ORC = BIC x ILM

= ៧៤.៨២៩ លានរៀល x ១

= ៧៤.៨២៩ លានរៀល

**ជំហានទី៤៖ គណនា RWA**

RWA = ORC x ១២,៥០

= ៧៤.៨២៩ លានរៀល x ១២,៥០

= ៩៣៥.៣៦៣ លានរៀល

បន្ទាប់ពីការគណនាតាមជំហានទី១ ដល់ជំហានទី៤ គ្រឹះស្ថានមានទិន្នន័យសម្រាប់បំពេញរបាយការណ៍ប្រចាំខែ ស្តីពី ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដូចខាងក្រោម៖

**របាយការណ៍ប្រចាំខែ ស្តីពី ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**

**Monthly Report on Risk-Weighted Assets (RWA) for Operational Risk in Deposit-taking Banks and Financial Institutions**

គិតជាលានរៀល

| ខ្ទង់ | ឆ្នាំ ២០២១ | ឆ្នាំ ២០២២ | ឆ្នាំ ២០២៣ | ជាមធ្យម |
|---|---|---|---|---|
| **១. សមាសធាតុការប្រាក់ ភតិសន្យា និងភាគលាភ**<br>**1. Interest, Leases and Dividend Component (ILDC)** | | | | **២៦៨.៥៩៧** |
| ចំណូលការប្រាក់<br>Interest income | ៣០០.០០០ | ៥០០.០០០ | ៧០០.០០០ | |
| ចំណាយការប្រាក់<br>Interest expense | ២២២.៤៣៨ | ២០៦.១៥៥ | ២៦៨.២៤១ | |
| តម្លៃដាច់ខាតនៃ (ចំណូលការប្រាក់ – ចំណាយការប្រាក់)<br>Abs (Interest income – Interest expense) | ៧៧.៥៦២ | ២៩៣.៨៤៥ | ៤៣១.៧៥៩ | ២៦៧.៧២២ |
| ទ្រព្យសកម្មដែលអាចរកបានចំណូលការប្រាក់<br>Interest earning assets | ២៥.៨៦០.០០០ | ២៨.៨៩៤.០០០ | ៣២.៣៧៣.០០០ | ២៩.០៤២.៣៣៣ |
| ចំណូលភាគលាភ<br>Dividend income | ៤៧៥ | ៤៨៣ | ១.៦៦៦ | ៨៧៥ |
| **២. សមាសធាតុសេវា**<br>**2. Services Component (SC)** | | | | **២២០.៧៨៧** |
| ចំណូលប្រតិបត្តិការផ្សេងៗ<br>Other operating income | ៣០.០០០ | ៥០.០០០ | ៧០.០០០ | ៥០.០០០ |
| ចំណាយប្រតិបត្តិការផ្សេងៗ<br>Other operating expense | ៦៤.៣៩១ | ៨២.២៧២ | ៨៧.៦៩៨ | ៧៨.១២០ |
| ចំណូលកម្រៃសេវា<br>Fee income | ១៣៦.០០០ | ១៤៣.០០០ | ១៤៩.០០០ | ១៤២.៦៦៧ |
| ចំណាយកម្រៃសេវា<br>Fee expense | ៥.០០០ | ៦.០០០ | ៩.០០០ | ៦.៦៦៧ |

| | | | | |
|---|---|---|---|---|
| **៣. សមាសធាតុហិរញ្ញវត្ថុ**<br>**3. Financial Component (FC)** | | | | **១.៣៣៣** |
| ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរ<br>Net P&L trading book | ២០០ | ៣៥០ | ៤៥០ | ៣៣៣ |
| ចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ<br>Net P&L banking book | ៦២០ | ១.០៣០ | ១.៣៥០ | ១.០០០ |
| **៤. កត្តាអាជីវកម្ម (៤) = (១) + (២) + (៣)**<br>**4. Business Indicator (BI) (4) = (1) + (2) + (3)** | | | | **៤៩០.៧១៧** |
| **៥. សមាសធាតុកត្តាអាជីវកម្ម (៥) = (៤) x មេគុណម៉ាជីណាល**<br>**5. Business Indicator Component (BIC) (5) = (4) x Marginal coefficients** | | | | **៧៤.៨២៩** |
| **៦. មេគុណការខាតបង់ផ្ទៃក្នុង**<br>**6. Internal Loss Multiplier (ILM)** | | | | **១** |
| **៧. ភាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យប្រតិបត្តិការ (៧) = (៥) x (៦)**<br>**7. Operational Risk Capital Requirement (ORC) (7) = (5) x (6)** | | | | **៧៤.៨២៩** |
| **៨. ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ (៨) = (៧) x ១២,៥០**<br>**8. RWA for Operational Risk (8) = (7) x 12.50** | | | | **៩៣៥.៣៦៣** |

បញ្ជាក់៖ គ្រប់ Row និង Column ទាំងអស់ត្រូវបំពេញលេខ ឬយ៉ាងហោចណាស់លេខសូន្យ (0) និងមិនអនុញ្ញាតឱ្យបំពេញលេខអវិជ្ជមានទេ។

## ខ- ការគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ ក្នុងករណីគ្រឹះស្ថានមិនមានទិន្នន័យគ្រប់ ៣ ឆ្នាំ

ដើម្បីគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ គ្រឹះស្ថានត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

**ជំហានទី១៖** គណនា BI

**ជំហានទី២៖** គណនា BIC

**ជំហានទី៣៖** គណនា ORC និង

**ជំហានទី៤៖** គណនា RWA

ឧទាហរណ៍៖ គ្រឹះស្ថានបានធ្វើប្រតិបត្តិការចាប់ពីខែសីហា ឆ្នាំ២០២២ និងមានទិន្នន័យដែលដកស្រង់ពីរបាយការណ៍ស្តីពី ចំណេញ-ខាត ដូចខាងក្រោម៖

គិតជាលានរៀល

| ខ្ទង់ | ខែសីហា-ធ្នូ ឆ្នាំ ២០២២ | ឆ្នាំ ២០២៣ |
|---|---|---|
| **១ ចំណូលការប្រាក់** | **៤៥០** | **២.០០០** |
| **២ ចំណាយការប្រាក់** | **១៤៤** | **៥០០** |
| **៣ ចំណូលសុទ្ធពីការប្រាក់** | **៣០៦** | **១.៥០០** |
| **៤ ចំណូលមិនមែនការប្រាក់** | **៧៧** | **២៧២** |
| ៤.១ ចំណូលភាគលាភ | - | ១០ |
| ៤.២ ចំណេញ/ខាតពីប្រតិបត្តិការហិរញ្ញវត្ថុ | ២៧ | ៧២ |
| ៤.២.១ ការវាយតម្លៃប្រចាំខែ និងការលក់មូលបត្រ | - | ៣០ |
| ៤.២.១.១ ចំណេញ | - | ៤០ |
| ៤.២.១.២ ចំណាយដែលកើតមាន | - | ១០ |
| ៤.២.២ ចំណេញ/ខាតសុទ្ធពីជំនួញប្តូរប្រាក់ | ២៧ | (១០) |
| ៤.២.៣ ប្រតិបត្តិការឧបករណ៍និស្សន្ទ | - | ៥០ |
| ៤.២.៤ ផ្សេងៗ | - | ២ |
| ៤.៣ កម្រៃជើងសា និងសោហ៊ុយ | ១០ | ៤០ |
| ៤.៣.១ ចំណូល | ២៩ | ២០០ |
| ៤.៣.២ ចំណាយដែលកើតមាន | ១៩ | ១៦០ |
| ៤.៤ ចំណូលមិនមែនប្រតិបត្តិការធនាគារ | ៩០ | ៣០៤ |
| ៤.៤.១ ក្នុងនោះទទួលបានពីការជួល | ៩០ | ១៥០ |
| **៥ ចំណេញ/ខាត ប្រតិបត្តិការដុល** | **៣៨៣** | **១.៧៧២** |
| **៦ ចំណាយប្រតិបត្តិការ** | **៣០៩** | **៧៨២** |
| ៦.១ បៀវត្សរ៍ និងប្រាក់ឈ្នួល | ៨៥ | ១១០ |
| ៦.២ តម្លៃឈ្នួល និងអត្ថប្រយោជន៍ និយោជិត និង នាយក | ៥ | ២០ |

| | | |
|---|---|---|
| ៦.៣ ការជួល និងភតិសន្យាដែលបានសង | ១០៥ | ៣៥៤ |
| ៦.៣.១ ចំណាយរំលស់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | ៦០ | ២៥៥ |
| ៦.៣.២ ចំណាយទាក់ទងនឹងភតិសន្យារយៈពេលខ្លី | ៣០ | ៨៥ |
| ៦.៣.៣ ចំណាយទាក់ទងនឹងភតិសន្យាដែលមានតម្លៃទាប | - | - |
| ៦.៣.៤ ចំណាយទាក់ទងនឹងភតិសន្យាដែលមានការទូទាត់ប្រែប្រួល | - | - |
| ៦.៣.៥ ចំណាយការជួលផ្សេងៗ | ១៥ | ៨២ |
| ៦.៤ ពន្ធអាករ ថ្លៃអាជ្ញាបណ្ណ និងផាកពិន័យ | ៦១ | ៩២ |
| ៦.៤.១ ពន្ធអាករ | ៥ | ១៥ |
| ៦.៤.២ ថ្លៃអាជ្ញាបណ្ណ និងផាកពិន័យ | ៥៦ | ៧៧ |
| ៦.៥ ចំណាយលើអាគារ ព្រមទាំងរំលស់ | - | - |
| ៦.៦ ចំណាយលើសម្ភារៈ | ១ | ៤ |
| ៦.៧ ចំណាយលើរំលស់លើទ្រព្យអរូបី | ២ | ៧ |
| ៦.៨ ចំណាយប្រតិបត្តិការផ្សេង | ៩០ | ១៩៥ |
| ៦.៨.១ ពីប្រតិបត្តិការធនាគារ | ៣០ | ១០៥ |
| ៦.៨.២ មិនមែនពីប្រតិបត្តិការធនាគារ | ៦០ | ៩០ |
| **៧ ចំណេញ/ខាត សុទ្ធពីប្រតិបត្តិការ** | **៧៤** | **៩៩០** |
| **៨ ខាត/ចំណេញពីចំណាយធ្វើសំវិធានធន និងការប្រមូលបានមកវិញ** | **(២៩)** | **(១២)** |
| ៨.១ ការខាតបង់ឥណទានរំពឹងទុក - ប្រាក់ដើម | ១២ | (៨) |
| ៨.២ ការខាតបង់ឥណទានរំពឹងទុក - ការប្រាក់ | (៤១) | (៥) |
| ៨.៣ ការខាតបង់ឥណទានរំពឹងទុក - ខ្ទង់ក្រៅតារាងតុល្យការ | - | (២) |
| ៨.៤ ការប្រមូលបានមកវិញ | - | ៣ |
| **៩ ការខាតបង់ឥណទានរំពឹងទុកចំពោះមូលបត្រនិងការបាត់បង់ពីការលុបភាគកម្មនៃសិទ្ធិចូលរួម** | **-** | **-** |
| **១០ ដើមទុនចំណេញ/ខាត ពីទ្រព្យសកម្មដែលមិនអាចប្រើប្រាស់បាន** | **-** | **-** |
| **១១ ចំណេញ/ខាត មុនធ្វើជំពូកអញ្ញាតិកម្ម** | **៤៥** | **៩៧៨** |
| **១២ ខ្ទង់អញ្ញាតិកម្មផ្សេងៗ** | **(៥)** | **៣** |
| ១២.១ ចំណេញធ្វើអញ្ញាតិកម្ម | - | - |
| ១២.២ ខាតធ្វើអញ្ញាតិកម្ម | - | (៣) |
| ១២.៣ ចំណេញ/ខាត សុទ្ធពីការបង្វែររូបិយប័ណ្ណបរទេស | (៥) | ៦ |
| **១៣ ចំណេញ/ខាត សុទ្ធមុនបង់ពន្ធ** | **៤០** | **៩៨១** |
| **១៤ ពន្ធលើប្រាក់ចំណេញ** | **៨** | **១៩៦** |
| **១៥ ចំណេញ/ខាត សុទ្ធក្នុងគ្រានេះ** | **៣២** | **៧៨៥** |
| **១៦ បង្គរចំណេញ/ខាត ពីដើមឆ្នាំមុននឹងបែងចែកប្រាក់ចំណេញ** | **-** | **-** |

| | | |
|---|---|---|
| **១៧ ផ្ទេរទៅទុនបម្រុង** | - | - |
| **១៨ ភាគលាភ** | - | - |
| **១៩ ផ្ទេរទៅទីស្នាក់ការកណ្តាលនៅ...(បង្ហាញប្រទេស)** | - | - |
| **២០ បង្គរចំណេញ/ខាត ពីបណ្តាឆ្នាំមុនបន្ទាប់ពីបែងចែកប្រាក់ចំណេញ** | **៣២** | **៧៨៥** |

គ្រឹះស្ថានត្រូវគណនាទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ សម្រាប់របាយការណ៍ខែមករា ឆ្នាំ២០២៤ ដូចខាងក្រោម៖

**ជំហានទី១៖ គណនា BI**

BI = ILDC + SC + FC

**១- ILDC**

គិតជាលានរៀល

| ខ្ទង់ | ខែ សីហា-ធ្នូ ឆ្នាំ ២០២២ | ឆ្នាំ ២០២២ (មូលដ្ឋានប្រចាំឆ្នាំ) | ឆ្នាំ ២០២៣ | ជាមធ្យម |
|---|---|---|---|---|
| ចំណូលការប្រាក់ | ៤៥០ | ១.០៨០ (៦) | ២.០០០ | |
| ចំណាយការប្រាក់ (៥) | ២៣៩ | ៥៦២ (៧) | ៨១២ | |
| តម្លៃដាច់ខាតនៃ (ចំណូលការប្រាក់ – ចំណាយការប្រាក់) | ២១៦ | ៥១៨ | ១.១៨៨ | ៨៥៣ |
| ទ្រព្យសកម្មដែលអាចរកបានចំណូលការប្រាក់ | ៨១០ | ១.៩៤៤ | ២.៥៣១ | ២.២៣៨ |
| ចំណូលភាគលាភ | - | - | ១០ | ៥ |

(៥) ចំណាយការប្រាក់ ដែលស្ថិតក្នុង ខ្ទង់ ២ ចំណាយការប្រាក់ និងខ្ទង់ ៦.៣ ការជួល និងភតិសន្យាដែលបានសង ប៉ុន្តែមិនបញ្ចូល ខ្ទង់ ៦.៣.៥ ចំណាយការជួលផ្សេងៗ (ទិន្នន័យដកស្រង់ពីរបាយការណ៍ស្តីពី ចំណេញ-ខាត)

ដើម្បីទទួលបាន BI សម្រាប់រយៈពេលពេញមួយឆ្នាំ២០២២ ដែលមានទិន្នន័យជាក់ស្តែងត្រឹមរយៈពេល ៥ ខែ (ខែសីហា ដល់ខែធ្នូ ឆ្នាំ២០២២) គ្រឹះស្ថានត្រូវគណនា BI ជាមធ្យមសម្រាប់រយៈពេល ៥ ខែ រួចគុណនឹង ១២ ដើម្បីទទួលបាន BI ដែលបង្ហាញលើមូលដ្ឋានប្រចាំឆ្នាំ។ របៀបគណនាមានដូចខាងក្រោម៖

(៦) $\frac{៤៥០}{៥} \times ១២ = ១.០៨០$ លានរៀល

(៧) $\frac{២៣៩}{៥} \times ១២ = ៥៦២$ លានរៀល

ILDC = អប្បបរមារវាង [ តម្លៃដាច់ខាតនៃ (ចំណូលការប្រាក់ – ចំណាយការប្រាក់) និង (២,២៥% x ទ្រព្យសកម្មដែលអាចរកបានចំណូលការប្រាក់ )] + ចំណូលភាគលាភ

= អប្បបរមារវាង [៨៥៣ លានរៀល និង (២,២៥% x ២.២៣៨ លានរៀល)] + ៥ លានរៀល

= អប្បបរមារវាង (៨៥៣ លានរៀល និង ៥០ លានរៀល) + ៥ លានរៀល

= ៥៥ លានរៀល

## ២- SC

គិតជាលានរៀល

| ខ្ទង់ | ខែ សីហា-ធ្នូ ឆ្នាំ ២០២២ | ឆ្នាំ ២០២២ (មូលដ្ឋានប្រចាំឆ្នាំ) | ឆ្នាំ ២០២៣ | ជាមធ្យម |
|---|---|---|---|---|
| ចំណូលប្រតិបត្តិការផ្សេងៗ [៨] | ៩០ | ២១៦ | ៣០៤ | ២៦០ |
| ចំណាយប្រតិបត្តិការផ្សេងៗ [៩] | ៨៦ | ២០៦ | ១៨២ | ១៩៤ |
| ចំណូលកម្រៃសេវា | ២៩ | ៧០ | ២០០ | ១៣៥ |
| ចំណាយកម្រៃសេវា | ១៩ | ៤៦ | ១៦០ | ១០៣ |

[៨] ចំណូលប្រតិបត្តិការផ្សេងៗដែលស្ថិតក្នុង ខ្ទង់ ៤.៤ ចំណូលមិនមែនប្រតិបត្តិការធនាគារ (ទិន្នន័យដកស្រង់ពីរបាយការណ៍ស្តីពី ចំណេញ-ខាត)

[៩] ចំណាយប្រតិបត្តិការផ្សេងៗដែលស្ថិតក្នុង ខ្ទង់ ៦.៨ ចំណាយប្រតិបត្តិការផ្សេង និងខ្ទង់ ៦.៤.២ ថ្លៃអាជ្ញាបណ្ណ និងផាកពិន័យ (ទិន្នន័យដកស្រង់ពីរបាយការណ៍ស្តីពី ចំណេញ-ខាត)

SC = អតិបរមារវាង (ចំណូលប្រតិបត្តិការផ្សេងៗ និង ចំណាយប្រតិបត្តិការផ្សេងៗ) + អតិបរមារវាង (ចំណូលកម្រៃសេវា និង ចំណាយកម្រៃសេវា)

= អតិបរមារវាង (២៦០ លានរៀល និង ១៩៤ លានរៀល) + អតិបរមារវាង (១៣៥ លានរៀល និង ១០៣ លានរៀល)

= ២៦០ លានរៀល + ១៣៥ លានរៀល

= ៣៩៥ លានរៀល

## ៣- FC

គិតជាលានរៀល

| ខ្ទង់ | ខែ សីហា-ធ្នូ ឆ្នាំ ២០២២ | ឆ្នាំ ២០២២ (មូលដ្ឋានប្រចាំឆ្នាំ) | ឆ្នាំ ២០២៣ | ជាមធ្យម |
|---|---|---|---|---|
| តម្លៃដាច់ខាតនៃ (ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរ) + តម្លៃដាច់ខាតនៃ (ចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ) [១០] | ២៧ | ៦៥ | ៧២ | ៦៩ |

[១០] ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរនិងចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារដែលស្ថិតក្នុង ខ្ទង់ ៤.២ ចំណេញ/ខាតពីប្រតិបត្តិការហិរញ្ញវត្ថុ (ទិន្នន័យដកស្រង់ពីរបាយការណ៍ស្តីពី ចំណេញ-ខាត)

FC = តម្លៃដាច់ខាតនៃ (ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរ) + តម្លៃដាច់ខាតនៃ (ចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ)

= ៦៩ លានរៀល

ជាលទ្ធផល BI = ILDC + SC + FC

= ៥៥ លានរៀល + ៣៩៥ លានរៀល + ៦៩ លានរៀល

= ៥១៩ លានរៀល

**ជំហានទី២៖ គណនា BIC**

BIC = BI x មេគុណម៉ាជីណាល

ដោយ BI ក្នុងជំហានទី១ ស្មើនឹង ៥១៩ លានរៀល គ្រឹះស្ថានត្រូវគណនា BIC តាមមូលដ្ឋានតាមថ្នាក់ ដោយប្រើប្រាស់កម្រិតចន្លោះ BI និងមេគុណម៉ាជីណាល ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

គិតជាលានរៀល

| **កម្រិតចន្លោះ BI និងមេគុណម៉ាជីណាល** | | | | **BIC** |
|---|---|---|---|---|
| **កម្រិត** | **កម្រិតចន្លោះ BI** | **BI** | **មេគុណម៉ាជីណាល** | |
| ១ | ≤ ១៥០.០០០ | ៥១៩ | ១២% | ៦២ |
| ២ | ១៥០.០០០ < BI ≤ ៣០០.០០០ | - | ១៥% | - |
| ៣ | > ៣០០.០០០ | - | ១៨% | - |
| **សរុប** | | **៥១៩** | | **៦២** |

**ជំហានទី៣៖ គណនា ORC**

ORC = BIC x ILM

= ៦២ លានរៀល x ១

= ៦២ លានរៀល

**ជំហានទី៤៖ គណនា RWA**

RWA = ORC x ១២,៥០

= ៦២ លានរៀល x ១២,៥០

= ៧៧៩ លានរៀល

បន្ទាប់ពីការគណនាតាមជំហានទី១ ដល់ជំហានទី៤ គ្រឹះស្ថានមានទិន្នន័យសម្រាប់បំពេញរបាយការណ៍ប្រចាំខែ ស្តីពី ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដូចខាងក្រោម៖

## របាយការណ៍ប្រចាំខែ ស្ដីពី ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ
## Monthly Report on Risk-Weighted Assets ( RWA ) for Operational Risk in Deposit-taking Banks and Financial Institutions

គិតជាលានរៀល

| ខ្ទង់ | ឆ្នាំ ២០២១ | ឆ្នាំ ២០២២ | ឆ្នាំ ២០២៣ | ជាមធ្យម |
|---|---|---|---|---|
| **១. សមាសធាតុការប្រាក់ ភតិសន្យា និងភាគលាភ**<br>**1. Interest, Leases and Dividend Component (ILDC)** | | | | **៥៥** |
| ចំណូលការប្រាក់<br>Interest income | - | ១.០៨០ | ២.០០០ | |
| ចំណាយការប្រាក់<br>Interest expense | - | ៥៦២ | ៨១២ | |
| តម្លៃដាច់ខាតនៃ (ចំណូលការប្រាក់ – ចំណាយការប្រាក់)<br>Abs (Interest income – Interest expense) | - | ៥១៨ | ១.១៨៨ | ៨៥៣ |
| ទ្រព្យសកម្មដែលអាចរកបានចំណូលការប្រាក់<br>Interest earning assets | - | ១.៩៤៤ | ២.៥៣១ | ២.២៣៨ |
| ចំណូលភាគលាភ<br>Dividend income | - | - | ១០ | ៥ |
| **២. សមាសធាតុសេវា**<br>**2. Services Component (SC)** | | | | **៣៩៥** |
| ចំណូលប្រតិបត្តិការផ្សេងៗ<br>Other operating income | - | ២១៦ | ៣០៥ | ២៦០ |
| ចំណាយប្រតិបត្តិការផ្សេងៗ<br>Other operating expense | - | ២០៦ | ១៨២ | ១៩៤ |
| ចំណូលកម្រៃសេវា<br>Fee income | - | ៧០ | ២០០ | ១៣៥ |
| ចំណាយកម្រៃសេវា<br>Fee expense | - | ៤៦ | ១៦០ | ១០៣ |

| | | | | |
|---|---|---|---|---|
| **៣. សមាសធាតុហិរញ្ញវត្ថុ**<br>**3. Financial Component (FC)** | | | | **៦៩** |
| ចំណេញ/ខាតសុទ្ធលើបញ្ជិកាជួញដូរ<br>Net P&L trading book | - | - | ៥០ | ២៥ |
| ចំណេញ/ខាតសុទ្ធលើបញ្ជិកាធនាគារ<br>Net P&L banking book | - | ៦៥ | ២២ | ៤៥ |
| **៤. កត្តាអាជីវកម្ម (៤) = (១) + (២) + (៣)**<br>**4. Business Indicator (BI) (4) = (1) + (2) + (3)** | | | | **៥១៩** |
| **៥. សមាសធាតុកត្តាអាជីវកម្ម (៥) = (៤) x មេគុណម៉ាជីណាល**<br>**5. Business Indicator Component (BIC) (5) = (4) x Marginal coefficients** | | | | **៦២** |
| **៦. មេគុណការខាតបង់ផ្ទៃក្នុង**<br>**6. Internal Loss Multiplier (ILM)** | | | | **១** |
| **៧. ភាតព្វកិច្ចដើមទុនសម្រាប់ហានិភ័យប្រតិបត្តិការ (៧) = (៥) x (៦)**<br>**7. Operational Risk Capital Requirement (ORC) (7) = (5) x (6)** | | | | **៦២** |
| **៨. ទ្រព្យសកម្មក្រោយថ្លឹងហានិភ័យសម្រាប់ហានិភ័យប្រតិបត្តិការ (៨) = (៧) x ១២,៥០**<br>**8. RWA for Operational Risk (8) = (7) x 12.50** | | | | **៧៧៩** |

បញ្ជាក់៖ គ្រប់ Row និង Column ទាំងអស់ត្រូវបំពេញលេខ ឬយ៉ាងហោចណាស់លេខសូន្យ (0) និងមិនអនុញ្ញាតឱ្យបំពេញលេខអវិជ្ជមានទេ។